01391521

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារលេខ D292/1/1/4

*ក្នុងនាមប្រជារាស្ត្រខ្មែរ និងក្នុងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៣០)

**ចំពោះមុខ:** ចៅក្រម ប្រាក់ គីមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៧

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 16 / 02 / 2017
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ:កោសលុប**

**សេចក្តីសម្រេចលើសំណើរបស់ [redacted] ស្នើសុំធ្វើមោឃភាពលើដីកាសម្រេច ឯកសារ D193/55, D193/57, D193/59 និង D193/61**

---

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីការពារក្តីម្ចាស់បណ្តឹងឧទ្ធរណ៍</u>**
មុំ លុច្ឆ
Richard ROGERS
Göran SLUITER

**<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Emmanuel JACOMY
Beini YE

**វ៉ែន ពៅ**

Linda BEHNKE

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើសុំធ្វើមោឃភាពលើដីកាសម្រេច ឯកសារ D193/55, D193/57, D193/59 និង D193/61" ដែលបានដាក់ដោយសហមេធាវីការពារក្តីរបស់ [redacted] (*ហៅ* "[redacted]" និង "[redacted]") ("មេធាវីការពារក្តី") នៅថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៦ ("សំណើសុំ")[1]។

## I. សេចក្តីផ្តើម

1. នៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ សំណើសុំនេះត្រូវបានដាក់ជូនទៅអង្គបុរេជំនុំជម្រះ ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") អនុលោមតាមវិធាន ៧៦(៣) នៃវិធានផ្ទៃក្នុង ("ដីកាសម្រេចស្តីពីការបញ្ជូនសំណុំរឿង")[2]។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ("ស.ព.អ") បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីនៅការិយាល័យរបស់សហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") ដោយចោទប្រកាន់ថា [redacted] មានការជាប់ពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋកម្ម[3]។

3. នៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៣ ស.ព.អ បានបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") ពីអត្ថិភាពនៃកំណត់ហេតុស្តាប់ចម្លើយសាក្សី និងខ្សែអាត់ថតសំឡេងនៃចម្លើយសាក្សីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ដែល ស.ព.អ បានបញ្ជាក់ថា អាចស្ថិតនៅក្រោមកាតព្វកិច្ចនៃ

---

[1] សំណើសុំធ្វើមោឃភាពលើដីកាសម្រេច ឯកសារ D193/55, D193/57, D193/59 និង D193/61 ចុះថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ D292/1/1/1។

[2] ដីកាសម្រេចលើសំណើរបស់ [redacted] សុំឱ្យអង្គបុរេជំនុំជម្រះ ធ្វើមោឃភាពដីកាសម្រេច D193/55, D193/57, D193/59 និង D193/61 ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ D292/1។ *សូមមើលផងដែរ* លិខិតពីក្រឡាបញ្ជីរបស់ ក.ស.ច.ស ដាក់ជូនទៅមន្ត្រីសំណុំរឿង ទាក់ទងនឹងការបញ្ជូនសំណុំរឿង ០០៤ ទៅអង្គបុរេជំនុំជម្រះ ឯកសារ D292/1 ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ D292/1/1។

[3] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1 កថាខណ្ឌ ១១៧ (គ)។ *សូមមើលផងដែរ* សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។

ការបង្ហាញរបស់គាត់ ទាក់ទងនឹងកិច្ចដំណើរការនីតិវិធីលើការជំនុំជម្រះសំណុំរឿង ០០២ /១៩-០៩-២០០៧ អ.វ.ត.ក/កសចស (សំណុំរឿង ០០២)[4]។ នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៣ អ.ជ.ស.ដ បានឆ្លើយតបថា "ដោយសារតែសហចៅក្រមស៊ើបអង្កេតទទួលសំណុំរឿង ០០៣ និង ០០៤ ហើយកំណត់ហេតុស្តាប់ចម្លើយដែលមានការពាក់ព័ន្ធ ស្ថិតក្នុងភាពសម្ងាត់នៃការស៊ើបអង្កេតដែលកំពុងដំណើរការ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេត ត្រូវតែសម្រេចជាមុនសិនថាតើអនុញ្ញាតផ្តល់នូវកំណត់ហេតុស្តាប់ចម្លើយទាំងនេះមកអង្គជំនុំជម្រះដែរឬទេ" ដោយបង្គាប់ឱ្យ ស.ព.អ "ដាក់សំណើនេះដោយផ្ទាល់ជូនទៅសហចៅក្រមស៊ើបអង្កេត ដើម្បីស្នើសុំឱ្យផ្តល់ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សីទាំងនេះ"[5]។

4. ចាប់ពីខែ តុលា ឆ្នាំ ២០១៥ មក ស.ព.អ បានស្វែងរកការអនុញ្ញាតពី ក.ស.ច.ស ដើម្បីដាក់បង្ហាញឯកសារពីការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤/១៩-០៩-២០០៧ អ.វ.ត.ក/កសចស (សំណុំរឿង០០៤) ទៅក្នុងកិច្ចដំណើរការនីតិវិធីលើការជំនុំជម្រះសំណុំរឿង ០០២ តាមរយៈការដាក់សំណើ ឯកសារ D193/45[6], D193/46[7], D193/48[8], D193/50[9], D193/52[10]

---

[4] ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីកំណត់ហេតុស្តាប់ចម្លើយសាក្សីពីសំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ E127/7។

[5] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង៖ ព័ត៌មានទាក់ទងនឹងចម្លើយសាក្សីនៅក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ដែលអាចពាក់ព័ន្ធនឹងសំណុំរឿង ០០២ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ E127/7/1។

[6] សំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D193/45។

[7] សំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D193/46។

[8] សំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D193/48។

[9] សំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D193/50។

[10] សំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D193/52។

និង D193/58[11] ដែលបានដាក់ នៅថ្ងៃទី ៧, ថ្ងៃទី ១៦, ថ្ងៃទី ២១, ថ្ងៃទី ២៦ និងថ្ងៃទី ៣០ ខែ តុលា និងថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៥ (ហៅជារួមថា "សំណើរបស់ ស.ព.អ")។ មេធាវីការពារក្តីបានឆ្លើយតបទៅនឹងសំណើរបស់ ស.ព.អ តាមរយៈការដាក់ឯកសារ D193/47[12], D193/49[13], D193/51[14], D193/53[15] និង D193/60[16] ដែលបានដាក់នៅថ្ងៃទី ១៩, ថ្ងៃទី ២៣, ថ្ងៃទី ២៨ ខែ តុលា, ថ្ងៃទី ៣ ខែ វិច្ឆិកា និងថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៥ ("ចម្លើយតបរបស់មេធាវីការពារក្តី")។ នៅក្នុងចម្លើយតបទីមួយ និងទីពីរ មេធាវីការពារក្តីបានស្នើឱ្យ ក.ស.ច.ស បដិសេធសំណើសុំដាក់បង្ហាញវត្ថុតាង ឬបង្គាប់ឱ្យ ស.ព.អ បង្ហាញពីកាលៈទេសៈពិសេសដែលធានាដល់ការដាក់បង្ហាញនៃឯកសារនីមួយៗ ដែលបានស្នើឡើង[17]។ នៅក្នុងចម្លើយតបទីបី និងទីបួន មេធាវីការពារក្តីបានបញ្ជាក់ថា ពួកគេមិនជំទាស់នឹងការដាក់បង្ហាញឯកសារនានាដែលបានស្នើឡើងនោះឡើយ ប្រសិនបើដីកាអនុញ្ញាតឱ្យដាក់បង្ហាញឯកសារនោះ ត្រូវបានសម្រេច

---

[11] សំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D193/58។

[12] ចម្លើយតបរបស់ [redacted] ទៅនឹងសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D193/47។

[13] ចម្លើយតបរបស់ [redacted] ទៅនឹងសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D193/49។

[14] ចម្លើយតបរបស់ [redacted] ទៅនឹងសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D193/51។

[15] ចម្លើយតបរបស់ [redacted] ទៅនឹងសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D193/53។

[16] ចម្លើយតបរបស់ [redacted] ទៅនឹងសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D193/60។

[17] ចម្លើយតបរបស់ [redacted] ទៅនឹងសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D193/47 កថាខណ្ឌ ៤៥ និង ៤៦។ ចម្លើយតបរបស់ [redacted] ទៅនឹងសំណើនានារបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារលេខ D193/46 និង D193/48 សុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D193/49 កថាខណ្ឌ ១៩ និង ២០។

រួម ដោយសហចៅក្រមស៊ើបអង្កេតទាំងពីរ[18]។ នៅថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ស.ព.អ បានដាក់ការឆ្លើយតបរួមមួយទៅនឹងចម្លើយតបនានារបស់មេធាវីការពារក្តី ដោយបានសន្និដ្ឋានថា វិធាន ៥៦(៣) នៃវិធានផ្ទៃក្នុង នៅពេលអានរួមគ្នាមួយនឹងវិធាន ៧២ នៃវិធានផ្ទៃក្នុង ផ្តល់ឱ្យសហចៅក្រមស៊ើបអង្កេតម្នាក់ៗនូវសិទ្ធិអំណាចក្នុងការដាក់បង្ហាញឯកសារជាឯកតោភាគី និងថាសំណើនានារបស់ ស.ព.អ បានបំពេញយ៉ាងត្រឹមត្រូវនូវលក្ខណៈវិនិច្ឆ័យសម្រាប់ការដាក់បង្ហាញឯកសារ[19]។ នៅថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ស.ច.ស.អ បានអនុញ្ញាតឱ្យដាក់បង្ហាញឯកសារដែល ស.ព.អ បានស្នើសុំនៅក្នុងនោះមាន *ជាអាទិ៍* សំណើនានារបស់គាត់ ចុះថ្ងៃទី ១៦ និង ២៦ ខែ តុលា ឆ្នាំ ២០១៥ ដោយស្ថិតនៅក្រោមការដាក់កំហិត និងទម្រង់បែបបទមួយចំនួន ដើម្បីការពារសុចរិតភាពនៃការស៊ើបអង្កេត (“ដីកាសម្រេចដែលរងការជំទាស់ទីមួយ”)[20]។

5. នៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ មេធាវីការពារក្តីបានដាក់សំណើនៅចំពោះមុខ ក.ស.ច.ស ដើម្បីស្វែងរកការបញ្ជាក់ថាតើ ស.ច.ស.អ បានពិចារណាពីចម្លើយតបនានារបស់មេធាវីការពារក្តីនៅពេលចេញដីកាសម្រេចដែលរងការជំទាស់ទីមួយ (សំណើសុំការបញ្ជាក់) ឬទេ[21]។

6. នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ស.ច.ស.អ បានចេញដីកាសម្រេចមួយទៀត ដែលអនុញ្ញាតឱ្យមានការដាក់បង្ហាញឯកសារដែលស្នើសុំដោយ ស.ព.អ ក្នុងសំណើរបស់ខ្លួន ចុះថ្ងៃទី ៣០ ខែ តុលា

---

[18] ចម្លើយតបរបស់ [redacted] ទៅនឹងសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារលេខ D193/50 សុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D193/51។ ចម្លើយតបរបស់ [redacted] ទៅនឹងសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារលេខ D193/52 សុំដាក់បង្ហាញឯកសារពីសំណុំរឿង០០៤ ចូលទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D193/53។

[19] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ [redacted] (D193/47, D193/49, D193/51 & D193/53) ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D193/54។

[20] ដីកាសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារសំណុំរឿង ០០៤ ចូលក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D193/55។

[21] សំណើសុំការបញ្ជាក់ចំពោះសេចក្តីសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២/១ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D193/56។

ឆ្នាំ ២០១៥ ដោយស្ថិតនៅក្រោមការដាក់កំហិត និងទម្រង់បែបបទមួយចំនួន ដើម្បីការពារសុចរិតភាពនៃការស៊ើបអង្កេត ("ដីកាសម្រេចដែលរងការជំទាស់ទីពីរ")[22]។

7. នៅថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៥ ស.ព.អ បានដាក់សំណើសុំដាក់បង្ហាញឯកសារមួយផ្សេងទៀត[23]។ នៅថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ស.ច.ស.អ បានចេញដីកាសម្រេចដែលអនុញ្ញាតឱ្យមានការបង្ហាញឯកសារដែលបានស្នើសុំ ("ដីកាសម្រេចដែលរងការជំទាស់ទី ៣")[24]។ នៅថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ២០១៥ មេធាវីការពារក្តីបានដាក់ចម្លើយតបទៅនឹងសំណើសុំដាក់បង្ហាញឯកសាររបស់ ស.ព.អ ដោយបញ្ជាក់ឡើងវិញពីសំណើនោះថា រាល់សេចក្តីបង្គាប់ពាក់ព័ន្ធនឹងការដាក់បង្ហាញឯកសារ ត្រូវចេញរួមគ្នាដោយសហចៅក្រមស៊ើបអង្កេត[25]។

8. នៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៥ ស.ច.ស.អ បានចេញដីកាសម្រេចដែលអនុញ្ញាតឱ្យមានការដាក់បង្ហាញឯកសារ ដែល ស.ព.អ បានស្នើសុំនៅក្នុងនោះមាន *ជាអាទិ៍* សំណើនានារបស់គាត់ ចុះថ្ងៃទី ៧ និង ២១ ខែ តុលា ឆ្នាំ ២០១៥ ("ដីកាសម្រេចដែលរងការជំទាស់ទី ៥")[26]។

9. នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ ស.ច.ស.អ បានចេញដីកាសម្រេចមួយដែលបដិសេធសំណើសុំការបញ្ជាក់ ("ដីកាសម្រេចលើសំណើសុំការបញ្ជាក់")[27]។ នៅក្នុងដីកាសម្រេចលើសំណើសុំការបញ្ជាក់នោះ ស.ច.ស.អ យល់ថាមិនមានភាពចាំបាច់ក្នុងការបញ្ឈប់ការដាក់បង្ហាញឯកសារជាឯកតោ

---

[22] ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ D193/52 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D193/57។

[23] សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿងលេខ ០០២ ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D193/58។

[24] ដីកាសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារ D193/58 ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D193/59។

[25] ចម្លើយតបរបស់ [redacted] ទៅនឹងសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ D193/58 សុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ៤ ខែ ធ្នូ ឯកសារ D193/60 កថាខណ្ឌ ២។

[26] ដីកាសម្រេចលើសំណើសុំបង្ហាញឯកសារ D193/29, D193/35, D193/38, D193/39, D193/42, D193/45, D193/46 និង D193/48 របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារ ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D193/61។

[27] ដីកាសម្រេចលើចម្លើយតបរបស់ [redacted] D193/47, D193/49, D193/51, D193/53, D193/56 និង D193/60 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D284។

ភាគី[28] ឬកែប្រែលក្ខខណ្ឌសម្រាប់ការដាក់បង្ហាញឯកសារ។ ស.ច.ស.អ បញ្ជាក់ក្នុងការចេញដីកាសម្រេចដែលរងការជំទាស់ទីមួយថា គាត់បានពិចារណាពីទឡ្ហីករណ៍របស់មេធាវីការពារក្ដី[29] ព្រមទាំងបានគូសបញ្ជាក់ថា គាត់ "មិនមានកាតព្វកិច្ចលើកឡើងដោយចំហាពីសារណារបស់ភាគីនីមួយៗស្ដីពីបញ្ហាអង្គច្បាប់ នៅពេលធ្វើសេចក្ដីសម្រេចឡើយ"[30]។ នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៦ មេធាវីការពារក្ដីបានប្ដឹងឧទ្ធរណ៍ស្ដីពីដីកាសម្រេចលើសំណើសុំការបញ្ជាក់ទៅអង្គបុរេជំនុំជម្រះ ដោយស្នើឱ្យអង្គបុរេជំនុំជម្រះបង្គាប់ឱ្យ ស.ច.ស.អ ច្រានចោលរាល់សេចក្ដីបង្គាប់ និងដីកាសម្រេចពីមុនស្ដីពីការដាក់បង្ហាញឯកសារ ("បណ្ដឹងឧទ្ធរណ៍សុំឱ្យមានការបញ្ជាក់")[31]។ អង្គបុរេជំនុំជម្រះបានច្រានចោលបណ្ដឹងឧទ្ធរណ៍នេះថា មិនអាចទទួលយកបាន កាលពីថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦[32]។

10. នៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៦ មេធាវីការពាក្ដីបានដាក់សំណើសុំនៅចំពោះមុខ ក.ស.ច.ស សុំឱ្យអង្គបុរេជំនុំជម្រះ ធ្វើមោឃភាពដីកាសម្រេចទីមួយ ទីពីរ ទីបី និងទីបួន[33]។ នៅថ្ងៃទី ១៩ ខែ

[28] ដីកាសម្រេចលើសំណើសុំការបញ្ជាក់ កថាខណ្ឌ ២០៖ "ខ្ញុំយល់ឃើញថា ការដាក់បង្ហាញឯកសារសំណុំរឿង 004 ដោយ ស.ច.ស តែម្នាក់ មិនត្រូវបានហាមឃាត់តាមវិធាន ៥៦ (២) ទេ ដែលវិធាននេះពាក់ព័ន្ធនឹងការផ្ដល់សិទ្ធិទៅសាធារណជន មិនថាជាស្ថាប័នសាធារណៈ ឬជាក់លាក់ណាមួយនោះទេ ហើយមិនមែនពាក់ព័ន្ធនឹងការដាក់បង្ហាញឯកសារទៅភាគីនៅចំពោះមុខអង្គភាពតុលាការផ្សេងទៀតរបស់ អ.វ.ត.ក ទេ។ *ខ្ញុំបានប្រឹក្សាជាមួយសហសេវិកជាតិរបស់ខ្ញុំ អំពីការយល់ឃើញរបស់ខ្ញុំស្ដីពីផែនកំណត់នៃវិធានផ្ទៃក្នុងនេះ តាមច្បាប់កម្ពុជា ហើយគាត់ចូលរួមចែករំលែកមតិយោបល់គតិយុត្តិនេះ"* ។

[29] ដីកាសម្រេចលើសំណើសុំការបញ្ជាក់ កថាខណ្ឌ ២៣។

[30] *ដូចជើងទំព័រខាងលើ*។

[31] បណ្ដឹងឧទ្ធរណ៍របស់ [redacted] ជំទាស់នឹងដីកាសម្រេចលើចម្លើយតបឯកសារ D193/47, D193/49, D193/51, D193/53, D193/56 និង D193/60 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ D284/1/2។

[32] សំណុំរឿងលេខ 00៤/0៧-0៩-២00៩-អវតក/កសចស ("សំណុំរឿង 00៤") (អបជ ២៥), សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ជំទាស់នឹងដីកាសម្រេចលើចម្លើយតប ឯកសារ D193/47, D193/49, D193/51, D193/53, D193/56 និង D193/60 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ("សាលដីកាលើសំណុំរឿង 00៤ (អបជ ២៥)"), ឯកសារ D284/1/4។

[33] សំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពដីកាសម្រេច ឯកសារ D193/55, D193/57, D193/59 និង D193/61 ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៦ ឯកសារ D292។

សីហា ឆ្នាំ ២០១៦ ស.ច.ស.អ បានទទួលសំណើរបស់មេធាវីការពារក្តី[34] ហើយនៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ស.ច.ស.អ បានបញ្ជូនសំណើនោះទៅអង្គបុរេជំនុំជម្រះ[35]។

11. នៅថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ អង្គបុរេជំនុំជម្រះបានចេញការណែនាំដល់ភាគីពាក់ព័ន្ធទាំងអស់ ដែលទទួលបានការជូនដំណឹងតាមអ៊ីមែលរបស់មន្ត្រីសំណុំរឿង ដែលណែនាំឱ្យមេធាវីការពារក្តី [redacted] ដាក់សំណើសុំនៅចំពោះមុខអង្គបុរេជំនុំជម្រះក្នុងរយៈពេល ១០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងនេះ ហើយប្រសិនបើគ្មានការដាក់សំណើសុំក្នុងកាលបរិច្ឆេទកំណត់នេះទេ អង្គបុរេជំនុំជម្រះនឹងកត់សម្គាល់លើសំណើសុំ ដែលបានដាក់នៅចំពោះមុខ ក.ស.ច.ស[36]។ នៅថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៦ មេធាវីការពារក្តីបានដាក់សំណើសុំនៅចំពោះមុខអង្គបុរេជំនុំជម្រះ[37]។ នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបទៅនឹងសំណើសុំនោះ ("ចម្លើយតប")[38]។ នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៦ មេធាវីការពារក្តីបានដាក់ការឆ្លើយតបទៅនឹងចម្លើយតបនោះ ("ការឆ្លើយតប")[39]។

## III. ភាពអាចទទួលយកបាន

12. វិធាន ៧៦(៤) នៃវិធានផ្ទៃក្នុង ចែងថា អង្គបុរេជំនុំជម្រះអាចប្រកាសថា ពាក្យសុំមោឃភាពនោះមិនអាចទទួលយកបាន ប្រសិនបើ (១) ពាក្យសុំមិនបានបង្ហាញហេតុផលគ្រប់គ្រាន់ (២) ពាក្យសុំ

---

34 ដីកាសម្រេចស្តីពីការបញ្ជូនសំណុំរឿង។

35 លិខិតពីក្រឡាបញ្ជីរបស់ ក.ស.ច.ស ដាក់ជូនទៅកាន់មន្ត្រីសំណុំរឿង ទាក់ទងនឹងការបញ្ជូនសំណុំរឿង ០០៤ ទៅអង្គបុរេជំនុំជម្រះ ឯកសារ D292/1 ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ D292/1/1។

36 សេចក្តីជូនដំណឹងរបស់មន្ត្រីទទួលបន្ទុកសំណុំរឿង ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦, ការណែនាំរបស់អង្គបុរេជំនុំជម្រះដល់ភាគីពាក់ព័ន្ធទាំងអស់ក្នុងសំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៣០)។

37 សំណើសុំធ្វើមោឃភាពលើដីកាសម្រេច ឯកសារ D193/55, D193/57, D193/59 និង D193/61 ចុះថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ D292/1/1/1។

38 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ [redacted] សុំធ្វើមោឃភាពលើដីកាសម្រេចឯកសារ D193/55, D193/57, D193/59 និង D193/61 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ D292/1/1/2។

39 ការឆ្លើយតបរបស់ [redacted] ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាលើសំណើរបស់ [redacted] សុំធ្វើមោឃភាពលើដីកាសម្រេច ឯកសារ D193/55, D193/57, D193/59 និង D193/61 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ D292/1/1/3។

នេះមានពាក់ព័ន្ធជាមួយដីកាដែលត្រូវប្តឹងឧទ្ធរណ៍ ឬ (៣) ពាក្យសុំនេះគ្មានមូលដ្ឋានច្បាស់លាស់[40]។ ទន្ទឹមនឹងនេះ អង្គបុរេជំនុំជម្រះត្រូវបញ្ជាក់ថាតើសំណើសុំធ្វើមោឃភាពបញ្ជាក់ពីផ្នែកនៃកិច្ចដំណើរការនីតិវិធីដែលប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់អ្នកដាក់សំណើសុំ[41] ធ្វើឱ្យមានការប៉ះពាល់ធម្មតា[42] និងប្រសិនបើដូច្នេះ និងក្នុងករណីចាំបាច់ បង្ហាញភស្តុតាងគ្រប់គ្រាន់ដើម្បីធ្វើការចោទប្រកាន់ ឬទេ[43]។

13. អង្គបុរេជំនុំជម្រះយល់ថា មានការបំពេញតាមលក្ខខណ្ឌក្នុងវិធាន ៧៦(៤) នៃវិធានផ្ទៃក្នុង។ ទីមួយ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ដីកាសម្រេចដែលរងការជំទាស់មិនបើកឱ្យ

---

[40] សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៣") (អបជ ២៨), សាលដីការបស់អង្គបុរេជំនុំជម្រះ ១) លើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងសំណើចំនួនប្រាំបួនរបស់ [redacted] សុំប្តឹងទៅអង្គបុរេជំនុំជម្រះឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ និង ២) លើសំណើចំនួនពីរដែលត្រូវបានបញ្ជូនដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ D165/2/26 (ដីកាសម្រេចលើ [redacted]") កថាខណ្ឌ ៥៥។

[41] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (""សំណុំរឿង ០០២) (អបជ ៤១), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1) ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D262/2/6 ("ដីកាសម្រេចលើ អៀង ធីរិទ្ធ") កថាខណ្ឌ ២៤។ *សូមមើលផងដែរ* សំណុំរឿង ០០២ (អបជ ៣០) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំធ្វើមោឃភាពដោយមូលហេតុរំលោភនីតិវិធី ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារ D197/5/8 កថាខណ្ឌ ២៤។

[42] *សូមមើល* សំណុំរឿង ០០២ (អបជ ០៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ឯកសារ D55/I/8 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៨ ("ដីកាសម្រេចលើ នួន ជា") កថាខណ្ឌ ៤០ ("ការបង្ហាញអំពីការរំលោភសិទ្ធិ [...] ដែលត្រូវបានទទួលស្គាល់នៅក្នុង ICCPR អាចបង្គ្រប់ជាកំហុសនីតិវិធី [...]។ នៅក្នុងករណីបែបនេះ កិច្ចស៊ើបសួរ ឬកិច្ចរបស់តុលាការអាចចាត់ទុកជាមោឃៈ") និងកថាខណ្ឌ ៤២ ("[ក្នុងករណីផ្សេងទៀត] ភាគីដែលដាក់ពាក្យសុំនឹងត្រូវបង្ហាញថា ផលប្រយោជន៍របស់ខ្លួន ត្រូវបានប៉ះពាល់ដោយសារកំហុសនីតិវិធី")។

[43] សំណុំរឿង ០០៣ (អបជ ២០) សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់ [redacted] ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D134/1/10 ("ដីកាសម្រេចលើ [redacted] ពាក់ព័ន្ធនឹងសំណើចំនួនពីរ") កថាខណ្ឌ ២២។

មានការប្ដឹងឧទ្ធរណ៍ អនុលោមវិធានផ្ទៃក្នុងបានឡើយ[44]។ លើសពីនេះ អង្គបុរេជំនុំជម្រះយល់ថា គ្មានចំណុចណាមួយក្នុងពាក្យសុំដែលលើកឡើងថា វាគ្មានមូលដ្ឋានអង្គហេតុ ឬអង្គច្បាប់ច្បាស់លាស់ដើម្បីរាំងស្ទះដល់សំណើសុំនោះឡើយ។ អង្គបុរេជំនុំជម្រះយល់បន្ថែមទៀតថា ការលើកហេតុផលក្នុងសំណើសុំគឺមានភាពគ្រប់គ្រាន់ ព្រោះវាមានសារណាយ៉ាងស៊ីសង្វាក់គ្នាត្រឹមត្រូវដោយមានហេតុផលអង្គច្បាប់អមដោយមូលដ្ឋានច្បាស់លាស់ ឬដោយមានឯកសារអង្គហេតុនៅក្នុងសំណុំរឿងនេះ។

14. ហេតុដូចនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើស្នើសុំនេះអាចទទួលយកបាន។

## IV. ការពិចារណាលើអង្គសេចក្តី

### ខ. សារណារបស់ភាគី

*១. សំណើសុំ*

15. មេធាវីការពារក្តីស្នើឱ្យអង្គបុរេជំនុំជម្រះ ធ្វើមោឃភាពដីកាសម្រេចដែលរងការជំទាស់ដោយឈរលើមូលដ្ឋានថា ដីកាសម្រេចទាំងនេះមានកំហុសឆ្គងផ្នែកនីតិវិធី និងថា កំហុសបែបនេះរំលោភលើសិទ្ធិរបស់ [redacted] ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[45]។ យោងតាមមេធាវីការពារក្តី ដីកាសម្រេចដែលរងការជំទាស់មានកំហុសឆ្គងផ្នែកនីតិវិធី ពីព្រោះដីកាសម្រេចទាំងនេះ៖ i) មិនត្រូវបានជូនដំណឹងដល់មេធាវីការពារក្តី ដែលរំលោភដល់លក្ខខណ្ឌតម្រូវនៃវិធាន ៤៦ នៃវិធានផ្ទៃក្នុង និងនៃមាត្រា ២.៥ មាត្រា ៣.១៥ និង មាត្រា ១១.១ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់

[44] សាលដីកាសំណុំរឿង ០០៤ (អបជ ២៥) កថាខណ្ឌ ២២ សូមមើលផងដែរសំណុំរឿង ០០៤ (អបជ២៩) សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍រួមរបស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ [redacted] សុំឱ្យពិចារណាឡើងវិញលើការដាក់បង្ហាញឯកសារ (D193/76និង D193/77) និងសំណើសុំដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D193/72) និងប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើ របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ (D193/70, D193/72, D193/75) ឯកសារលេខ D193/91/7 ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ កថាខណ្ឌ៣២។

[45] សំណើសុំ។

ឯកសារ និងនៃមាត្រា ២(ឃ)(ii) នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ថ្នាក់ឯកសារ[46] និង ii) មិនទទួលស្គាល់ការដាក់ឯកសារពាក់ព័ន្ធរបស់មេធាវីការពារក្តី ឬមិនបានលើកឡើងពីទឡ្ហីករណ៍ដែលមាន ហេតុដូចនេះរំលោភវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង អនុលោមតាមភារកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការធ្វើសេចក្តីសម្រេចដែលមានសំអាងហេតុគ្រប់គ្រាន់ដែល "មានន័យថាទឡ្ហីករណ៍របស់ភាគីលើបញ្ហាដែលកំពុងត្រូវបានចាត់ការ យ៉ាងហោចណាស់ត្រូវផ្តល់ការទទួលស្គាល់ និងការវាយតម្លៃជាអប្បបរមា"[47]។

16. មេធាវីការពារក្តីលើកឡើងថា កំហុសឆ្គងផ្នែកនីតិវិធីទាំងនេះរំលោភលើសិទ្ធិជាសារវន្តរបស់អ្នកដាក់សំណើសុំ ដូចជាសិទ្ធិប្តឹងឧទ្ធរណ៍ជំទាស់សេចក្តីសម្រេចរបស់តុលាការ សិទ្ធិទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុ សិទ្ធិមានភាពស្មើគ្នាចំពោះមុខតុលាការ និងសមភាពនៃមធ្យោបាយក្នុងការតទល់ក្តីគ្នា និងសិទ្ធិចូលរួមប្រកបដោយប្រសិទ្ធភាព មិនលម្អៀង និងសុចរិតភាពនៃការស៊ើបអង្កេត[48]។ ទាក់ទងនឹងសិទ្ធិប្តឹងឧទ្ធរណ៍ ទីមួយ មេធាវីការពារក្តីអះអាងថា៖ វា "ត្រូវបានទទួលស្គាល់យ៉ាងខ្ជាប់ខ្ជួននៅ អ.វ.ត.ក" ដែល [redacted] មានសិទ្ធិប្តឹងឧទ្ធរណ៍ជំទាស់ដីកា "ណាមួយ" ដែលបានចេញក្នុងរឿងក្តីរបស់គាត់[49] ហើយទីពីរ ចោទប្រកាន់ថា នៅក្នុងសំណុំរឿងនេះ សិទ្ធិរបស់ [redacted] ក្នុងការប្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចដែលរងការជំទាស់ ត្រូវបានរំលោភ ដោយសារកំហុសឆ្គងផ្នែកនីតិវិធី ដែលមានចែងក្នុងសំណើសុំនេះ មានជាអាទិ៍ i) កង្វះការជូនដំណឹងដល់មេធាវីការពារក្តីនៃដីកាសម្រេចដែលរងការជំទាស់ ដែលផាត់ចេញ [redacted] ពីការដាក់ជូនការជូនដំណឹងឲ្យទាន់ពេលវេលា និងការដាក់ជូនបណ្តឹងឧទ្ធរណ៍ និង ii)

---

[46] សំណើសុំ កថាខណ្ឌ ៤០-៤១ និងជើងទំព័រ ៥៧-៥៩។

[47] សំណើសុំ កថាខណ្ឌ ៤៤-៤៥ ដោយសំដៅលើ សំណុំរឿង ០០២ (អបជ ៦៧) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីសំណើសុំដាក់បញ្ចូលឯកសារភ័ស្តុតាងទៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិឡើង ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ D365/2/10 កថាខណ្ឌ ២២ កថាខណ្ឌ ២៤-២៥។

[48] សំណើសុំ កថាខណ្ឌ ៤៧-៦០។

[49] សំណើសុំ កថាខណ្ឌ ៤៨ *ដោយសំដៅលើ* សំណើសុំ កថាខណ្ឌ ៣២៖ "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានតម្រូវឲ្យការពារសិទ្ធិទាំងឡាយដែលមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយអនុលោមតាមកិច្ចព្រមព្រៀង [...] និង [ច្បាប់ស្តីពី] អ.វ.ត.ក"។

កង្វះសំអាងហេតុគ្រប់គ្រាន់នៅក្នុងដីកាសម្រេចដែលរងការជំទាស់ដែលដាក់បន្ទុកបន្ថែមទៀតដល់លទ្ធភាពរបស់ [redacted] ក្នុងការប្ដឹងឧទ្ធរណ៍[50]។ លើសពីនេះទៀត នៅក្នុងទស្សនៈរបស់មេធាវីការពារក្ដី "ក្រៅពី វាជាធាតុផ្សំដ៏សំខាន់នៃសិទ្ធិប្ដឹងឧទ្ធរណ៍ សិទ្ធិទទួលបានសេចក្ដីសម្រេចដែលមានសំអាងហេតុ គឺជាសិទ្ធិជាសារវន្តក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌" ហើយកង្វះការទទួលស្គាល់ការដាក់ឯកសារ និងទឡ្ហីករណ៍របស់មេធាវីការពារក្ដីនៅក្នុងដីកាសម្រេចដែលរងការជំទាស់ បង្កឲ្យមានការរំលោភដល់សិទ្ធិជាសារវន្តនេះ[51]។ មេធាវីការពារក្ដីលើកឡើងបន្ថែមទៀតថា សិទ្ធិរបស់ [redacted] ក្នុងការទទួលបានការប្រព្រឹត្តិដោយស្មើភាពគ្នា និងសមភាពនៃមធ្យោបាយក្នុងការតទល់ក្ដីគ្នា ត្រូវបានរំលោភ ពីព្រោះថា ក្នុងពេល ស.ព.អ បានទទួលសិទ្ធិផ្នែកនីតិវិធីរបស់គាត់ទាំងអស់នោះ [redacted] ត្រូវបានគេបដិសេធដោយមិនសមហេតុផល តាមរយៈដីកាសម្រេចដែលរងការជំទាស់៖ i) ត្រូវបានជូនដំណឹងដល់ ស.ព.អ តែប៉ុណ្ណោះ និង ii) ត្រូវបានទទួលស្គាល់ និងពិចារណាយ៉ាងជាក់លាក់តែលើការដាក់ឯកសារ និងទឡ្ហីករណ៍របស់ ស.ព.អ ប៉ុណ្ណោះ[52]។ យោងតាមមេធាវីការពារក្ដី គ្មានហេតុផលសមស្រប ឬឥតលម្អៀងណាមួយសម្រាប់ការប្រព្រឹត្តិដោយវិសមភាពនោះទេ[53]។ មេធាវីការពារក្ដីបន្តអះអាងថា កង្វះការជូនដំណឹងអំពីដីកាសម្រេចដែលរងការជំទាស់ ត្រូវបានរឹតបន្តឹងជ្រុលហួសហេតុទៅលើលទ្ធភាពរបស់ [redacted] ក្នុងការតាមដានកិច្ចដំណើរការនីតិវិធី និងផ្ដល់ការណែនាំតាមការចាំបាច់ ដូច្នេះរំលោភលើសិទ្ធិរបស់គាត់ក្នុងការចូលរួមប្រកបដោយប្រសិទ្ធភាព[54]។ លើសពីនេះទៀត ប្រព្រឹត្តិកម្មចំពោះទឡ្ហីករណ៍ និងឯកសារដែល [redacted] បានដាក់ គឺមានវិសមភាពជាមួយទឡ្ហីករណ៍ និងឯកសារដែលសហព្រះរាជអាជ្ញាបានដាក់ ដែលបានបង្កើតឲ្យមានការយល់ឃើញថាមានភាពលម្អៀង[55]។

---

[50] សំណើសុំ កថាខណ្ឌ ៤៨-៥១។

[51] សំណើសុំ កថាខណ្ឌ ៥២។

[52] សំណើសុំ កថាខណ្ឌ ៥៣-៥៥។

[53] សំណើសុំ កថាខណ្ឌ ៥៦។

[54] សំណើសុំ កថាខណ្ឌ ៥៨។

[55] សំណើសុំ កថាខណ្ឌ ៥៩។

ជាចុងក្រោយ មេធាវីការពារក្ដីលើកឡើងថា ជាសរុប ការរំលោភទាំងនេះបានប៉ះពាល់ដល់សុចរិតភាពនៃការស៊ើបអង្កេត[56]។

*២. ចម្លើយតបរបស់ ស.ព.អ*

17. ស.ព.អ លើកឡើងថា បើទោះជាវិធាន ៤៦ នៃវិធានផ្ទៃក្នុង តម្រូវឱ្យមានការជូនដំណឹងដល់ភាគីអំពីសេចក្ដីសម្រេចក៏ដោយ ក៏វាមិនបានចែងអំពីទម្រង់ណាមួយដែលតម្រូវឱ្យមាននៅក្នុងការជូនដំណឹងនោះឡើយ[57]។ ស.ព.អ យោងលើយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះដែលលើកឡើងថា ពុំមានលក្ខខណ្ឌតម្រូវជាក់លាក់ណាមួយក្នុងច្បាប់ជាធរមាននោះឡើយ សម្រាប់ដីកាសម្រេចលើការដាក់បង្ហាញឯកសារដែលមានសំអាងហេតុ[58]។ យោងតាម ស.ព.អ អ្នកដាក់សំណើសុំខកខានមិនបានបង្ហាញពីផលប៉ះពាល់ណាមួយ ដែលបណ្ដាលមកពីការរំលោភសិទ្ធិដែលគាត់បានអះអាង[59]។ តាមទស្សនៈរបស់ ស.ព.អ ការរំលោភសិទ្ធិដែលត្រូវបានចោទប្រកាន់ដោយអ្នកដាក់សំណើសុំត្រូវបានទប់ស្កាត់រួចហើយដោយដីកាសម្រេចលើសំណើសុំការបញ្ជាក់[60] ដែលត្រូវបានប្ដឹងឧទ្ធរណ៍រួចហើយ ដូចដែល ស.ព.អ បានគូសបញ្ជាក់ ហើយអង្គបុរេជំនុំជម្រះបានចាត់ការលើទឡ្ហីករណ៍ទាំងនេះរួចហើយដែរ [61]។

*៣. ការឆ្លើយតបរបស់មេធាវីការពារក្ដី*

18. មេធាវីការពារក្ដីលើកឡើងម្ដងហើយម្ដងទៀតពីទឡ្ហីករណ៍ចំពោះវិការៈផ្នែកនីតិវិធី[62] និងអះអាងបន្ថែមទៀតថា ការពឹងផ្អែករបស់សហព្រះរាជអាជ្ញាអន្តរជាតិលើយុត្តិសាស្ត្ររបស់អង្គបុរេជំនុំ

---

[56] សំណើសុំ កថាខណ្ឌ ៦០។

[57] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ១៤។

[58] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ១៥ *ដោយយោង* ជើងទំព័រ ៣០ នៃសំណុំរឿង ០០៤ (អ.ប.ជ២៦) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងការផ្ដល់សក្ខីកម្មនៅពេលជំនុំជម្រះនៅក្នុងសវនាការអសាធារណៈ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៦ ឯកសារ D309/6 (សាលដីកា សំណុំរឿង ០០៤ (អបជ ២៦)) កថាខណ្ឌ ៣៨។

[59] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ២១។

[60] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ១៨។

[61] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ១៩។

[62] ការឆ្លើយតប, កថាខណ្ឌ ៤។

ជម្រះ ដើម្បីបង្ហាញថា "ហេតុផលមិនមែនជាលក្ខខណ្ឌតម្រូវ" គឺជាការអនុវត្តខុសឆ្គង ពីព្រោះនៅក្នុងបរិបទនៃសេចក្តីសម្រេចដែលបានដកស្រង់ កង្វះខាតនៃការផ្តល់សំអាងហេតុលម្អិតត្រូវតែមានយុត្តិកម្មតាមរយៈអង្គហេតុដែលថា ស.ច.ស.អ បានលើកឡើងពីហេតុផលរបស់ខ្លួននៅក្នុងអនុស្សរណៈមុនមួយ ក្នុងពេលដែលស្ថិតក្នុងករណីបច្ចុប្បន្ន ទឡ្ហីករណ៍របស់មេធាវីការពារក្តី គឺមិនបានបញ្ជាក់ នៅក្នុងសេចក្តីសម្រេច ឬអនុស្សរណៈណាមួយពីមុននោះទេ[63]។ យោងតាមមេធាវីការពារក្តី ដីកាសម្រេចលើសំណើសុំការបញ្ជាក់មិនបានលើកឡើងពីវិការៈនានាដែលបានលើកឡើងនៅក្នុងសំណើសុំនេះ ហើយវិការៈទាំងនេះក៏មិនមែនជាចំណុចវិវាទ ឬជាខ្លឹមសារសំខាន់នៅក្នុងបណ្តឹងឧទ្ធរណ៍នោះទេ[64]។ លើសពីនេះ ដោយសារកង្វះការជូនដំណឹងនោះ ដីកាសម្រេចដែលរងការជំទាស់ទាំងបីត្រូវបានមេធាវីការពារក្តីដឹង ក្រោយពេលវេលាកំណត់ ហើយអាស្រ័យហេតុនេះ ដីកាសម្រេចលើសំណើសុំការបញ្ជាក់ និងបណ្តឹងឧទ្ធរណ៍ក្រោយមកទៀត គឺមិនអាចកែប្រែការពិតដែលថា [redacted] បានបាត់បង់សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចទាំងនេះ[65]។ ចុងក្រោយ មេធាវីការពារក្តីអះអាងថា សហព្រះរាជអាជ្ញាអន្តរជាតិច្របាច់បញ្ចូលគ្នានូវបញ្ហានៃភាពលម្អៀង ដែលបានកើតឡើងដោយការដាក់បង្ហាញឯកសារ រួមទាំងបញ្ហាដែលបានកើតឡើងដោយកង្វះខាតនៃការផ្តល់សំអាងហេតុគ្រប់គ្រាន់ និងការជូនដំណឹងអំពីដីកាសម្រេចដែលរងការជំទាស់[66]។

## ខ. ការពិភាក្សា

19. អង្គបុរេជំនុំជម្រះរំឭកថា ការធ្វើមោឃភាពអាចត្រូវបានប្រមើលឃើញ ដោយអនុលោមតាមវិធាន ៤៨ នៃវិធានផ្ទៃក្នុង ដែលចែងថា "កិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះអាចត្រូវបានចាត់ទុកជាមោឃៈតែចំពោះករណីមិនគោរពវិធានបញ្ញត្តិដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគី ដែលដាក់ពាក្យសុំប៉ុណ្ណោះ"។[67] អាស្រ័យហេតុនេះ ភាពមិនប្រក្រតីផ្នែកនីតិវិធីដែលមិនប៉ះពាល់ដល់អ្នក

---

[63] ការឆ្លើយតប, កថាខណ្ឌ ៥។

[64] ការឆ្លើយតប, កថាខណ្ឌ ៦។

[65] ការឆ្លើយតប, កថាខណ្ឌ ៦ *យោងទៅលើ* ដីកាសម្រេចទី ២, ៣ និង ៤។

[66] ការឆ្លើយតប, កថាខណ្ឌ ៧។

[67] អ.វ.ត.ក វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិសោធនកម្មនៅថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៥ (វិធានផ្ទៃក្នុង)។

ដាក់ពាក្យសុំមិននាំឲ្យមានការធ្វើមោឃភាពឡើយ[68]។ ជាបន្តទៀតនេះ អង្គបុរេជំនុំជម្រះត្រូវពិនិត្យទឡ្ហីករណ៍របស់អ្នកដាក់សំណើសុំចំពោះវិការៈផ្នែកនីតិវិធី និងការរំលោភបំពានសិទ្ធិនៅក្នុងករណីនេះ។

*ខ.១. សេចក្តីសម្រេចដែលមានសំអាងហេតុ*

20. អង្គបុរេជំនុំជម្រះធ្វើការយោងលើបទប្បញ្ញត្តិនានានៃវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង ដែលចែងត្រង់ចំណុចពាក់ព័ន្ធថា៖

"សេចក្តីសម្រេចទាំងអស់ស្ថិតក្នុងវិធាននេះ រួមទាំងគំនិតជំទាស់ផង ត្រូវមានសំអាងហេតុ និងចុះហត្ថលេខាដោយចៅក្រមទាំងនេះ"។

21. អង្គបុរេជំនុំជម្រះរំឭកបន្ថែមពីយុត្តិសាស្ត្ររបស់ខ្លួនដែលពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវឲ្យមានសេចក្តីសម្រេចដែលមានសំអាងហេតុ ដោយបញ្ជាក់ថា វាជាបទដ្ឋានអន្តរជាតិដែលថា *សេចក្តីសម្រេចទាំងអស់របស់ស្ថាប័នតុលាការចាំបាច់ត្រូវតែមានការផ្តល់សំអាងហេតុ*[69] ។ ទាក់ទងនឹងបទដ្ឋានសម្រាប់ភាពជាក់លាក់ក្នុងការផ្តល់សំអាងហេតុ បើយោងតាមអង្គបុរេជំនុំជម្រះ៖

"សហចៅក្រមស៊ើបអង្កេតមាន*ឆន្ទានុសិទ្ធិ* - ដែលអាចពិនិត្យមើលដោយអង្គបុរេជំនុំជម្រះ (...)-*ដើម្បីសម្រេចអំពីកម្រិតក្នុងការផ្តល់ចំណុចលម្អិតគ្រប់គ្រាន់ ដែលជាលក្ខខណ្ឌតម្រូវ*តាមក្របខ័ណ្ឌច្បាប់នៃ អ.វ.ត.ក។ សហចៅក្រមស៊ើបអង្កេត *ត្រូវអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដោយគោរពតាមគោលបំណងនៃលក្ខខណ្ឌតម្រូវ [ដែលមានចែងក្នុងវិធានជាក់លាក់]* ក្នុងការបដិសេធដោយមានសំអាងហេតុ... [វាមិនមែនជាការចាំបាច់] ក្នុងការបង្ហាញឲ្យអស់នូវគ្រប់ចំណុចលម្អិតអំពី "ព័ត៌មានទាំងអស់ដែលមាននៅក្នុងសំណុំ

---

[68] សាលដីកា [redacted] ទៅលើពាក្យសុំទាំងពីរ" កថាខណ្ឌ ២៦ *យោងទៅលើ* សាលដីកា អៀង ធីរិទ្ធ កថាខណ្ឌ ២១។

[69] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវកត/កសចស ("សំណុំរឿង ០០១ ") (អបជ ០២), សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើសំណើរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច", ថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 កថាខណ្ឌ ៣៨។ *សូមមើលផងដែរ* សាលដីកា នួន ជា កថាខណ្ឌ ២១។

រឿង"។ ផ្ទុយទៅវិញ [...] *សហចៅក្រមស៊ើបអង្កេតគួរបានផ្តល់ឲ្យយ៉ាងហោចណាស់ព័ត៌មានគំរូដែលយកចេញពីព័ត៌មាន* ក្នុងករណីសមស្រប អាចជាលេខឯកសារដែលពាក់ព័ន្ធ"[70]។

22. ជាងនេះទៀត អង្គបុរេជំនុំជម្រះបានគូសបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេត "មិនមានកាតព្វកិច្ចផ្តល់ការយល់ឃើញរបស់ខ្លួនលើកក្តាទាំងអស់ឡើយ [នៅក្នុងវិធានជាក់លាក់] ដោយសារ *កាតព្វកិច្ចបង្ហាញហេតុផលដែលគ្រាន់តែបញ្ជាក់ថា ពួកគេបានបង្ហាញអង្គហេតុ និងអង្គច្បាប់ដែលត្រូវយកមកពិចារណា* មុនពេលចេញសេចក្តីសម្រេច"[71]។ ដោយផ្អែកលើឧទាហរណ៍ទាំងនេះ នៅពេលសំណើរបស់ភាគីមួយត្រូវបានច្រានចោលនោះ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា៖

> "ទាំងភាគីដែលសំណើរបស់ខ្លួនត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះត្រូវដឹងអំពីមូលហេតុនៃការបដិសេធនោះឲ្យបានលម្អិតគ្រប់គ្រាន់ដើម្បីឲ្យដើមបណ្តឹងឧទ្ធរណ៍សម្រេចបានថាតើត្រូវប្តឹងឧទ្ធរណ៍ ឬទេ ហើយបណ្តឹងនោះគួរផ្អែកលើមូលដ្ឋានអ្វី [...] និងដើម្បីឲ្យអង្គបុរេជំនុំជម្រះមានលទ្ធភាពសម្រេចថាតើសហចៅក្រមស៊ើបអង្កេតមានកំហុសដែរឬទេ" [72]។

23. ផ្នែកដែលមានភាពពាក់ព័ន្ធបំផុតទៅនឹងករណីនេះ បន្ទាប់ពីបានប្រឈមមុខនឹងបណ្តឹងឧទ្ធរណ៍មួយផ្សេងទៀតប្រឆាំងនឹងសាលដីកាស្តីពីការដាក់បង្ហាញឯកសាររបស់ ស.ច.ស.អ អង្គជំនុំបុរេជំនុំជម្រះបានសង្កេតឃើញថា៖

> "ខុសពីកាតព្វកិច្ចជាក់លាក់ក្នុងការបង្ហាញសំអាងហេតុក្នុងការច្រានចោលកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង [...] *សហចៅក្រមស៊ើបអង្កេតពុំមានបន្ទុកជាក់លាក់ក្នុងការ*

---

[70] សំណុំរឿង ០០២ (អបជ ៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស ចំពោះសំណើសុំ D153, D172, D173, D174, D178 & D284, ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D300/1/5, កថាខណ្ឌ ៤៣។ សូមមើលផងដែរ សំណុំរឿង ០០២ (អបជ ៦២) ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ" ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១០, ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០ (អៀង ធីរិទ្ធិ អបជ២៦ )ឯកសារ D353/2/3, កថាខណ្ឌ ៣០។

[71] សំណុំរឿង ០០២ (អបជ០៣) ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨, សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន, ឯកសារ C22/I/73 កថាខណ្ឌ ៦៦។

[72] អៀង ធីរិទ្ធ អបជ៦២ កថាខណ្ឌ ២៨។

*ផ្តល់ដីកាសម្រេចស្តីពីការដាក់បង្ហាញឯកសារដែលមានសំអាងហេតុ អនុលោមតាមបទប្បញ្ញត្តិជាធរមាន ទាក់ទងនឹងកិច្ចស៊ើបសួរនៅចំពោះមុខ អ.វ.ត.ក ឡើយ"*[73] ។

24. នៅក្នុងសាលដីកានោះ អង្គបុរេជំនុំជម្រះក៏បានយល់ឃើញថា "[សហចៅក្រមស៊ើបអង្កេតអន្តរជាតិ] *បានផ្តល់ហេតុផលគ្រប់គ្រាន់* នៅពេលសម្រេចក្នុងដីកាសម្រេចដែលរងការជំទាស់ថាខ្លួន *"បានពិនិត្យឡើងវិញនូវបញ្ជីឈ្មោះសាក្សី និងសម្ភារៈដែលពួកគេបានដាក់បង្ហាញ"* និងបានបង្គាប់ឱ្យមានវិធានការពិសេសសម្រាប់ការបង្ហាញសាក្សីខ្លះ "អាស្រ័យទៅតាមលក្ខណៈសម្ងាត់ និងរសើបនៃកិច្ចស៊ើបសួរដែលកំពុងបន្តធ្វើឡើង"[74]។

25. នៅពេលពិនិត្យទឡ្ហីករណ៍របស់មេធាវីការពារក្តីពាក់ព័ន្ធនឹងចំណុចនេះ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដីកាសម្រេចដែលរងការជំទាស់ពិតជាបានផ្តល់សំអាងហេតុដែលបំពេញបទដ្ឋានកំណត់ដោយយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ចំពោះមូលហេតុដែលត្រូវលើកឡើងនៅក្នុងសេចក្តីសម្រេចរបស់ ក.ស.ច.ស ស្តីពីការដាក់បង្ហាញឯកសារ[75]។ អាស្រ័យហេតុនេះ ទឡ្ហីករណ៍របស់មេធាវីការពារក្តីដែលថា មូលហេតុនានាក្នុងដីកាសម្រេចដែលរងការជំទាស់រងការប៉ះពាល់ពីព្រោះ ស.ច.ស.អ មិនបាន *ដឹង* ពីការដាក់ឯកសាររបស់មេធាវីការពារក្តីនោះ អង្គបុរេជំនុំជម្រះទីមួយ សូមរំឭកថា បទដ្ឋានដែលបានបង្កើតឡើងសម្រាប់ការផ្តល់សំអាងហេតុសម្រាប់សេចក្តីសម្រេចមិនតម្រូវឱ្យមាន "ការទទួលស្គាល់លើការដាក់ឯកសាររបស់ភាគី" ច្បាស់លាស់នោះទេ ហើយទីពីរកត់សម្គាល់ថា ស.ច.ស.អ ផ្ទុយទៅវិញបានទទួលស្គាល់យ៉ាងច្បាស់លាស់លើចម្លើយតបរបស់មេធាវីការពារក្តី ដែលមានទឡ្ហីករណ៍ស្រដៀងគ្នាសម្រាប់សំណើសុំបង្ហាញឯកសារនីមួយៗ នៅក្នុងដីកាសម្រេចដែលរងការជំទាស់ ដែលនៅក្នុងដីកានេះ គាត់បានបញ្ជាក់ថា ដោយ

---

[73] សំណុំរឿង ០០៤ (អបជ ២៦) កថាខណ្ឌ ៣៨។

[74] *ដូចឯកសារយោងខាងលើ។*

[75] ដីកាសម្រេចដែលរងការជំទាស់លើកទី ១, ឯកសារ D193/55, កថាខណ្ឌ ៩-១១; ដីកាសម្រេចដែលរងការជំទាស់លើកទី ២, ឯកសារ D193/57 កថាខណ្ឌ ១០-១២; ដីកាសម្រេចដែលរងការជំទាស់លើកទី ៣, ឯកសារ D193/59, កថាខណ្ឌ ៧-៩; ដីកាសម្រេចដែលរងការជំទាស់លើកទី ៤, ឯកសារ D193/61 កថាខណ្ឌ ១៨-២២។

ពិចារណាលើលក្ខណៈបន្ទាន់នៃសំណើសុំដាក់បង្ហាញឯកសារ ការឆ្លើយនឹងត្រូវបង្ហាញ "នៅក្នុងសេចក្តីសម្រេចបន្ទាប់" [76] ហើយគាត់បានធ្វើដូច្នេះនៅក្នុងដីកាសម្រេចលើសំណើសុំការបញ្ជាក់[77]។

26. ដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចថា ដីកាសម្រេចដែលរងការជំទាស់បំពេញលក្ខខណ្ឌដែលបានកំណត់សម្រាប់ការផ្តល់សំអាងហេតុនៃសេចក្តីសម្រេចដាក់បង្ហាញឯកសាររបស់ ក.ស.ច.ស ហើយជាលទ្ធផល ពុំមានវិការៈផ្នែកនីតិវិធីនោះទេ។

*ខ.២. សេចក្តីជូនដំណឹងអំពីដីកាសម្រេច*

27. អង្គបុរេជំនុំជម្រះយោងបទប្បញ្ញត្តិក្នុងវិធាន ៤៦(១) នៃវិធានផ្ទៃក្នុងដែលមានចែងត្រង់ចំណុចពាក់ព័ន្ធថា៖

> "រាល់ដីកាទាំងអស់របស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះត្រូវជូនដំណឹងដល់ភាគី ឬមេធាវីរបស់ភាគីដោយផ្ទាល់មាត់ ឬផ្ញើទៅអាសយដ្ឋានចុងក្រោយរបស់គេ [...] តាមមធ្យោបាយសមស្រប"។

28. ជាងនេះទៀត ការយោងត្រូវបានធ្វើឡើងដល់បទប្បញ្ញត្តិនៃមាត្រា ២.១ មាត្រា ២.៥ មាត្រា ៣.១៥ និងមាត្រា ១១.១ នៃសេចក្តីណែនាំអនុវត្ត ស្តីពីការដាក់ឯកសារ និងមាត្រា ២(ឃ)(ii) នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ថ្នាក់ឯកសារ ដែលមានចែងត្រង់ចំណុចពាក់ព័ន្ធដូចខាងក្រោម៖

*មាត្រា ២.១ នៃសេចក្តីណែនាំស្តីពីការដាក់ឯកសារ*

---

[76] ដីកាសម្រេចដែលរងការជំទាស់លើកទី ២, ឯកសារ D193/57 កថាខណ្ឌ ១០៖ "ដោយពិចារណាអំពីលក្ខណៈបន្ទាន់នៃសំណើរបស់ ស.ព.អ ទាក់ទងទៅនឹងឯកសារ D219/297 យើងមិនសម្រេចលើឯកសារ D193/29 ត្រង់ចំណុចដែលវាត្រួតជាមួយសំណើនេះ។ សារណារបស់មេធាវីការពារក្តី [redacted] ស្តីពីការដាក់បង្ហាញសម្ភារៈនៃសំណុំរឿង ០០៤ ទៅសំណុំរឿង ០០២ នឹងត្រូវបានចាត់ការដាច់ដោយឡែកក្នុងដីកាសម្រេចមួយដែលនឹងមាននាពេលខាងមុខ"។ *សូមមើលផងដែរ* ដីកាសម្រេចដែលរងការជំទាស់លើកទី ២ ជើងទំព័រ ១៣។

[77] ដីកាសម្រេចលើសំណើសុំការបញ្ជាក់ កថាខណ្ឌ ២៣៖ "ទឡ្ហីករណ៍ដែលមាននៅក្នុងចម្លើយតប D193/47 ហើយបញ្ចូលតាមការយោងនៅក្នុង D193/49 និង D193/51 និង ទឡ្ហីករណ៍ដែលមាននៅក្នុង D193/53 *ត្រូវបានយកមកពិចារណានៅពេលដែលចេញដីកាសម្រេច D193/55*"។

ការដាក់ឯកសារនៅ អ.វ.ត.ក និងការទំនាក់ទំនងទៅវិញទៅមកជាមួយបុគ្គលដែលមានសិទ្ធិដាក់ឯកសារត្រូវធ្វើដោយផ្ទាល់ជាមួយក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត"។

*មាត្រា ២.៥ នៃសេចក្តីណែនាំស្តីពីការដាក់ឯកសារ*

វិធីចម្បងសម្រាប់ការដាក់ឯកសារគឺត្រូវដាក់តាមប្រព័ន្ធអេឡិចត្រូនិក។

*មាត្រា ៣.១៥ នៃសេចក្តីណែនាំស្តីពីការដាក់ឯកសារ*

ភាគីដាក់ឯកសារដែលស្នើសុំដាក់ចំណាត់ថ្នាក់ឯកសារ "សម្ងាត់បំផុត" ត្រូវសរសេររៀបរាប់នៅលើទំព័រទី១ នៃឯកសារ (ឧបសម្ព័ន្ធ ខ" ដោយដាក់ថា "ជូនចំពោះ" ឈ្មោះបុគ្គលទាំងអស់ ក្រៅពីមន្ត្រីតុលាការ ដែលភាគីនោះស្នើសុំឲ្យមានការផ្តល់សិទ្ធិមើលឯកសារមើលឯកសារ។

*មាត្រា ១១.១ នៃសេចក្តីណែនាំស្តីពីការដាក់ឯកសារ*

បុគ្គលដែលដាក់ឯកសារត្រូវទទួលការជូនដំណឹងតាមរយៈប្រព័ន្ធអេឡិចត្រូនិកអំពីឯកសារដែលបានដាក់ពីក្រឡាបញ្ជីដែលពាក់ព័ន្ធ។ បុគ្គលដែលដាក់ឯកសារត្រូវជូនដំណឹងអំពីអាសយដ្ឋានអ៊ីមែលណាមួយ ដែលខ្លួនចង់ឲ្យក្រឡាបញ្ជីដែលពាក់ព័ន្ធផ្ញើការជូនដំណឹងទៅ។

*មាត្រា ២(ឃ)(ii) នៃសេចក្តីណែនាំស្តីពីចំណាត់ប្រភេទឯកសារ*

"សម្ងាត់" មានន័យថា បើកចំហជូនចំពោះតែចៅក្រម សហព្រះរាជអាជ្ញា មេធាវី ភាគីដើមបណ្តឹង មេធាវីការពារក្តី បុគ្គលិកតុលាការដែលមានសិទ្ធិ និងអ្នកទាំងឡាយណាដែលមានសិទ្ធិពិនិត្យឯកសារ តាមសេចក្តីសម្រេចរបស់តុលាការមុន។

29. អង្គបុរេជំនុំជម្រះ ទីមួយ គត់សម្គាល់ថា មាត្រានៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារដែលបានស្នើឡើង ចាំបាច់ត្រូវអានរួមគ្នាជាមួយនឹងមាត្រា ២.១ ដែលយោងតាមចំណុចនេះ លក្ខខណ្ឌតម្រូវដែលបានលើកឡើងក្នុងមាត្រាទាំងនេះត្រូវបានចែងអំពីការដាក់ឯកសារពីសំណាក់ភាគី នានា និងមិនមែនសម្រាប់ដីកាសម្រេចដែលចេញដោយសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះណាមួយឡើយ។ ម្យ៉ាងវិញទៀត វិធាន ៤៦ នៃវិធានផ្ទៃក្នុង មិនបានចែងពីករណីលើកលែង នៅពេលសម្រេចថា ដីកា "ទាំងអស់" របស់សហចៅក្រមស៊ើបអង្កេតត្រូវតែជូនដំណឹងដល់ "ភាគីទាំងអស់" នោះទេ។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដីកាសម្រេចដែលរងការជំទាស់នីមួយៗនៅលើ

ទំព័រទី១ មានតែឈ្មោះសហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល។ មេធាវីការពារក្តីតវ៉ាថា ខ្លួនមិនទទួលបានការជូនដំណឹងអំពីដីកាសម្រេចដែលរងការជំទាស់នោះទេ[78] លើកលែងចំពោះដីកាសម្រេចដែលរងការជំទាស់លើកទីមួយប៉ុណ្ណោះ[79]។ អង្គបុរេជំនុំជម្រះសម្រេចថា អនុលោមតាមវិធាន ៤៦ នៃវិធានផ្ទៃក្នុង ស.ច.ស.អ ចាំបាច់ត្រូវជូនដំណឹងដល់មេធាវីការពារក្តីអំពីដីកាសម្រេចដែលរងការជំទាស់ឡើយ។ ជាបន្តទៀតនេះ អង្គជំនុំជម្រះនឹងពិនិត្យទឡ្ហីករណ៍របស់អ្នកដាក់សំណើសុំពាក់ព័ន្ធនឹងការរំលោភបំពានលើសិទ្ធិជាសារវន្តរបស់គាត់។

*ខ.៣. សិទ្ធិរបស់* [redacted]

30. ទាក់ទងទៅនឹងសិទ្ធិប្តឹងឧទ្ធរណ៍ ការយោងត្រូវបានធ្វើឡើងទាក់ទងនឹងបទប្បញ្ញត្តិក្នុងវិធាន ៧៥(១)(៣) នៃវិធានផ្ទៃក្នុង និងមាត្រា ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលចែងថា កាលបរិច្ឆេទចុងក្រោយក្នុងការដាក់បណ្តឹងឧទ្ធរណ៍ ចាប់ផ្តើមគិតពី "កាលបរិច្ឆេទដែលសេចក្តីជូនដំណឹងស្តីពីដីកាសម្រេច ឬ*ដីកាត្រូវបានទទួល*"។ ទីមួយ អង្គបុរេជំនុំជម្រះសង្កេតឃើញថា បើទោះបីជាមានការទទួលស្គាល់ថា ខ្លួនបានទទួលសេចក្តីជូនដំណឹងអំពីដីកាសម្រេចលើកទី ១ ដែលរងការជំទាស់ក៏ដោយ ក៏ [redacted] មិនបានដាក់បណ្តឹងឧទ្ធរណ៍នៅក្នុងរយៈពេលកំណត់តាមផ្លូវច្បាប់ទេ[80] ប៉ុន្តែផ្ទុយទៅវិញ ស្វែងរកការបំភ្លឺពី ស.ច.ស.អ[81] និងប្តឹងឧទ្ធរណ៍ប្រឆាំងនឹង

---

[78] សំណើសុំ, កថាខណ្ឌ ២(ក)។

[79] សំណើសុំ, ជើងទំព័រ ៥៖ "ករណីលើកលែង ចំពោះដីកាសម្រេច ឯកសារ D193/55 (ដីកាសម្រេច ចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥), ដែល *បានជូនដំណឹងដល់មេធាវីការពារក្តី* តាមរយៈអ៊ីមែល ប៉ុន្តែមិនបានដាក់បញ្ចូលក្រុមមេធាវីការពារក្តី ក្នុងបញ្ជីអ្នកទទួល នៅក្នុងអង្គភាព "ចែកចាយ" នោះទេ។ " *សូមមើលផងដែរ* សំណើសុំការបញ្ជាក់, កថាខណ្ឌ ១: "ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ [redacted] តាមរយៈសហមេធាវី ("មេធាវីការពារក្តី") របស់គាត់ទទួលបានការជូនដំណឹងអំពីសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") លើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២/០១ ("សេចក្តីសម្រេចរបស់ ស.ច.ស.អ") និង ជើងទំព័រ ១ *ដែលយោងទៅលើ* ឯកសារ D193/55។

[80] វិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង។

[81] សំណើសុំការបញ្ជាក់។

ដីកាសម្រេចលើសំណើសុំការបញ្ជាក់[82]។ ទីពីរ អង្គបុរេជំនុំជម្រះសម្រេចថា ដោយសារតែ [redacted] មិនទទួលបានការជូនដំណឹងអំពី ឬទទួលបានដីកាសម្រេចលើកទីពីរ ទីបី ដែលរងការជំទាស់ គាត់នៅតែមានសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចទាំងនេះ។

31. ជាងនេះទៀត ទាក់ទងនឹងសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចដែលរងការជំទាស់ទាំងនេះ អង្គបុរេជំនុំជម្រះគត់សម្គាល់ថា នៅក្នុងសំណើសុំមោឃភាពនេះ មេធាវីការពារក្តីអះអាងថា លក្ខខណ្ឌនៃច្បាប់ជាធរមាន ដើម្បីឱ្យ អ.វ.ត.ក ការពារសិទ្ធិរបស់ជនត្រូវចោទ ចែងអំពីសិទ្ធិរបស់ [redacted] ក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា "*ទាំងអស់*"។ ទីមួយ អង្គបុរេជំនុំជម្រះរំឭកថា កន្លងមកខ្លួនមិនបានរកឃើញមូលដ្ឋានផ្លូវច្បាប់ដើម្បីប្តឹងឧទ្ធរណ៍ក្នុងករណីដូចគ្នាស្តីពី *ការដាក់បង្ហាញឯកសារ* របស់ [redacted] ទាក់ទងនឹងដីកាសម្រេចលើសំណើសុំការបញ្ជាក់នោះទេ[83] ហើយគត់សម្គាល់ថា នៅក្នុងសំណើសុំមោឃភាពនេះ មេធាវីការពារក្តីមិនបានបង្ហាញបន្ថែមថា [redacted] មានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចដាក់បង្ហាញឯកសារ។ ទីពីរ ដោយសារតែកង្វះការជូនដំណឹងអំពីដីកាសម្រេចដែលរងការជំទាស់មួយចំនួនដល់មេធាវីការពារក្តី អង្គជំនុំជម្រះសម្រេចថា កិច្ចអន្តរាគមន៍របស់ខ្លួនដើម្បីទប់ស្កាត់ការខូចខាត *ដែលមិនអាចជួសជុលបាន* ដល់ភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬដល់សិទ្ធិជាសារវន្តរបស់ [redacted] គឺមិនចាំបាច់ឡើយ នៅក្នុងកាលៈទេសៈនៃសំណុំរឿងនេះ ពីព្រោះ [redacted] បានជ្រើសរើសផងដែរ ក្នុងការទាញយកប្រយោជន៍ពី*ការជួសជុលដែលមានស្រាប់* តាមរយៈការដាក់ពាក្យសុំមោឃភាពនេះតែម្តង[84]។

---

[82] បណ្តឹងឧទ្ធរណ៍លើសំណើសុំការបញ្ជាក់។

[83] ដីកាសម្រេចក្នុងសំណុំរឿង ០០៤ អបជ ២៥។ *សូមមើលផងដែរ* បណ្តឹងឧទ្ធរណ៍លើសំណើសុំការបញ្ជាក់, កថាខណ្ឌ ៥ ៧៨៖ "មេធាវីការពារក្តី ស្នើសុំដោយគោរពដល់អង្គបុរេជំនុំជម្រះ មេត្តាទុកជាមោឃៈនូវដីកាសម្រេចដែលរងការជំទាស់ និងបង្គាប់ឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិលុបចោលនូវដីកាសម្រេច និងសេចក្តីសម្រេចទាំងអស់ពីមុនៗ ស្តីពីការដាក់បង្ហាញសម្ភារៈពីក្នុងសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ដែលផ្អែកលើកំហុសនានាដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ"។

[84] ដីកាសម្រេចក្នុងសំណុំរឿង ០០៤ អបជ ២៥, កថាខណ្ឌ ២១: "គោលការណ៍ជាសារវន្តដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលបានឆ្លុះបញ្ចាំងពីលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះប្រកបដោយយុត្តិធម៌រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ("កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក") មាត្រា ៣៥ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អាចត្រូវ អ.វ.ត.ក អនុម័តយកការបកស្រាយបែបទូលាយអំពីសិទ្ធិ

*សេចក្តីសម្រេចលើសំណើរបស់* [redacted] *ស្នើសុំធ្វើមោឃភាពលើដីកាសម្រេចឯកសារ D193/55, D193/57, D193/59 និង D193/61*

យោងតាមច្បាប់ជាធរមាន ភាគីទាំងអស់អាចដាក់ពាក្យសុំមោឃភាព "*ក្នុងពេលណាមួយ* ក្នុងពេលស៊ើបអង្កេតតាមផ្លូវតុលាការ"[85]។ ចុងក្រោយ ដូចបានបង្ហាញយ៉ាងលម្អិតខាងលើក្នុងផ្នែក "ខ.១" នៃសេចក្តីសម្រេចនេះ អង្គជំនុំសម្រេចមិនផ្តល់អង្គសេចក្តីដល់ទឡ្ហីករណ៍របស់មេធាវីការពារក្តីចំពោះការរំលោភបំពានដល់សិទ្ធិក្នុងការទទួលបានសេចក្តីសម្រេច ដោយមានសំអាងហេតុឡើយ ដោយសារ "កង្វះការទទួលស្គាល់លើការដាក់ឯកសារ និងទឡ្ហីករណ៍របស់មេធាវីការពារក្តីនៅក្នុងដីកាសម្រេចដែលរងការជំទាស់"។ ដូច្នេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា គ្មានការរំលោភបំពានលើសិទ្ធិណាមួយក្នុងការប្តឹងឧទ្ធរណ៍ដែលបានកើតឡើងឡើយ។

32. អង្គបុរេជំនុំជម្រះបានឯកភាពរួចហើយថា វិធាន ៤៦ នៃវិធានផ្ទៃក្នុង តម្រូវឱ្យ ស.ច.ស.អ ជូនដំណឹងដល់មេធាវីការពារក្តីនូវដីកាសម្រេចដែលរងការជំទាស់ ទោះបីយ៉ាងណាក៏ដោយ ដោយសារតែអត្ថិភាពនៃការជួសជុលដែលមានប្រសិទ្ធភាព អង្គបុរេជំនុំជម្រះសម្រេចថា គ្មានការខូចខាតដែលត្រូវបានបង្កឡើងដល់សិទ្ធិជាសារវន្តរបស់ [redacted] ក្នុងការទទួលបានការប្រព្រឹត្តិស្មើគ្នា ឬសមភាពនៃមធ្យោបាយក្នុងការតទល់ក្តីគ្នាឡើយ។ អង្គបុរេជំនុំជម្រះសម្រេចបន្ថែមទៀតថា ទោះបីជាកង្វះការជូនដំណឹង ដូចមានបង្ហាញនៅក្នុងការដាក់សំណើសុំនេះ លទ្ធភាពរបស់ [redacted] ក្នុង

---

ក្នុងការប្តឹងឧទ្ធរណ៍ ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីមានភាពយុត្តិធ៌ និងចំពោះមុខ ហើយរក្សាបាននូវតុល្យភាពរបស់សិទ្ធិភាគី។ ក្នុងករណីអង្គហេតុ និងកាលៈទេសៈជាក់ស្តែងនៃរឿងក្តីដែលតម្រូវនោះ អង្គបុរេជំនុំជម្រះបានទទួលយកបណ្តឹងឧទ្ធរណ៍ដែលលើកឡើងពីបញ្ហានៃសិទ្ធិជាសារវន្ត ឬ "បញ្ហាធ្ងន់ធ្ងរនៃភាពយុត្តិធម៌" អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។ ប៉ុន្តែ វិធាន ២១ នៃវិធានផ្ទៃក្នុងមិនបានផ្តល់នូវមធ្យោបាយស្វ័យប្រវត្តិសម្រាប់បណ្តឹងឧទ្ធរណ៍ដែលលើកឡើងពីទឡ្ហីករណ៍ផ្អែកលើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តធម៌ឡើយ។ ដើម្បីឱ្យអង្គបុរជំនុំជម្រះអនុវត្តយុត្តាធិការក្នុងការពិនិត្យលើបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធានដែលបានលើកឡើង ម្ចាស់បណ្តឹងឧទ្ធរណ៍ចាំបាច់ត្រូវបង្ហាញថា នៅក្នុងកាលៈទេសៈជាក់លាក់នៃរឿងក្តីដែលកំពុងពិនិត្យនេះការអន្តរាគមរបស់អង្គបុរេជំនុំជម្រះគឺជាការចាំបាច់ ដើម្បីរាំងព្យសនម្មដែលមិនអាចជួសជុលបានចំពោះភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ម្ចាស់បណ្តឹងឧទ្ធរណ៍"។ *សូមមើលផងដែរ* ពាក្យសុំ, កថាខណ្ឌ ៦២: ការធ្វើបណ្តឹងឧទ្ធរណ៍ជំទាស់ ដីកាសម្រេចដែលរងការជំទាស់ បើទោះបីជាអាចធ្វើទៅបានតាមនីតិវិធីក៏ដោយ ក៏ក្នុងការអនុវត្តជាក់ស្តែងមិនអាចធ្វើទៅបានឡើយ ដោយកង្វះសំអាងហេតុទាក់ទងនឹងទឡ្ហីការណ៍របស់ក្រុមមេធាវីការពារក្តី។ ហេតុដូចនេះបញ្ហាចោទពុំមែនជាកំហុសអង្គហេតុ អង្គច្បាប់ ឬឆន្ទានុសិទ្ធិ ដែលរកមិនឃើញក្នុងសេចក្តីសម្រេចដែលគ្មានសំអាងហេតុគ្រប់គ្រាន់ឡើយ ប៉ុន្តែ ជាវិការៈផ្នែកនីតិវិធី និងការរំលោភសិទ្ធិដែលបណ្តាលមកពីការធ្វើដីកាសម្រេចទាំងនោះ"។

[85] វិធាន ៧៦(២) នៃវិធានផ្ទៃក្នុង។

ការបន្តតាមដានកិច្ចដំណើរការនីតិវិធីក្នុងគោលបំណងនៃការផ្តល់សេចក្តីណែនាំដល់មេធាវីការពារក្តី មិនត្រូវបានប៉ះពាល់ឡើយ។

33. ជាងនេះទៀត ក្រោយពីមានការសម្រេចថា ១)គ្មានការខូចខាតត្រូវបានបង្កឡើងដល់សិទ្ធិរបស់ [redacted] ក្នុងការទទួលបានការប្រព្រឹត្តិដូចគ្នា និងសមភាពនៃមធ្យោបាយក្នុងការតទល់ក្តីគ្នា និង ២) ដីកាសម្រេចដែលរងការជំទាស់បំពេញបទដ្ឋាន ដែលបានចែងសម្រាប់ការផ្តល់សំអាងហេតុនៃសេចក្តីសម្រេចដាក់បង្ហាញឯកសាររបស់ ក.ស.ច.ស នោះ អង្គបុរេជំនុំជម្រះ មិនរកឃើញអង្គសេចក្តីនៅក្នុងទឡ្ហីករណ៍ដែលថា ទស្សនទាននៃការលម្អៀងត្រូវបង្កើតឡើង ដោយសារតែការប្រព្រឹត្តិលើការដាក់ឯកសារ និងទឡ្ហីករណ៍របស់ [redacted] នៅក្នុងដីកាសម្រេចដែលរងការជំទាស់ឡើយ។

34. ចុងក្រោយ អង្គបុរេជំនុំជម្រះសម្រេចថា ទឡ្ហីករណ៍លើសុចរិតភាពនៃការស៊ើបអង្កេតដែលរងការប៉ះពាល់ ដែលផ្អែកទាំងស្រុងលើការសន្មតដែលថា ការរំលោភបំពានលើសិទ្ធិផ្សេងៗទៀត បានកើតឡើង ក៏ពុំមានមូលដ្ឋានដែរ។ អង្គជំនុំជម្រះក៏បានរកឃើញថា ច្បាប់ជាធរមានមិនបានផ្តល់ឱ្យជនត្រូវចោទនូវ "សិទ្ធិជាចាំបាច់" ក្នុងការទួលបានសុចរិតភាពក្នុងកិច្ចស៊ើបសួរឡើយ[86]។

35. ដូច្នេះ ដោយសារថា កង្វះការជូនដំណឹងមិនបានបង្កឱ្យមានការប៉ះពាល់ណាមួយនោះ អង្គបុរេជំនុំជម្រះសម្រេចថា កង្វះនៃភាពស៊ីសង្វាក់គ្នាជាមួយនឹងលក្ខខណ្ឌតម្រូវនៃវិធាន ៥៦ នៃវិធានផ្ទៃក្នុងមិននាំឱ្យមានវិការៈផ្នែកនីតិវិធី ដែលនាំឱ្យមានមោឃភាពឡើយ។

## គ. សេចក្តីសន្និដ្ឋាន

36. ដោយផ្អែកលើមូលហេតុទាំងអស់ដែលបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា មេធាវីការពារក្តីមិនបានបង្ហាញឱ្យឃើញថា ករណីនេះនាំដល់ការធ្វើមោឃភាពនៃដីកាសម្រេចដែលរងការជំទាស់ឡើយ។

[86] សាលដីកាក្នុងសំណុំរឿង ០០៤ អបជ២៥ កថាខណ្ឌ ២៣។

សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/កសចស (អបជ៣០)

ឯកសារលេខ D292/1/1/4

# សេចក្តីសម្រេច

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

**ច្រានចោល**សំណើសុំនេះ។

អនុលោមតាមវិធាន ៧៧(១៣ នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវប្តឹងឧទ្ធរណ៍។

**រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៧**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គិមសាន** **Olivier BEAUVALLET** **ន័យ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**